pennsylvania
DEPARTMENT OF EDUCATION

ជូនចំពោះ មាតាបិតា/អាណាព្យាបាល៖

ក្នុងសម័យដែលប្រើ ទូរស័ព្ទដៃ ស្មាតហ្វូន (smartphones) និងគ្រឿងអេឡិចត្រូនិចផ្សេងទៀត ដែលអាចថតចម្លងបានយ៉ាងងាយ ហើយចែកចាយគ្នាមើលបានយ៉ាងឆាប់រហ័ស ឯកសារសម្រាប់ប្រឡងដែលត្រូវរក្សាទុកជាសម្ងាត់ និងដោយសុវត្ថិភាព អាចបើកចំហជាសាធារណៈ។ ការប្តូរឯកសារប្រឡងដែលបានបើកចំហជាសាធារណៈនេះ មិនមែនគ្រាន់តែមានតម្លៃថ្លៃនោះទេ ឯកសារដែលមាននៅក្នុងការប្រឡង PSSA និង Keystone គឺជាកម្មសិទ្ធិរបស់រដ្ឋធិនស៊ីលវេញ៉ា ដែលគេត្រូវរក្សាសិទ្ធិ។ ការចម្លងឯកសារនៃការវាយតម្លៃ រួមទាំងការថតរូបភាព គឺជាបទល្មើសនឹងច្បាប់រក្សាសិទ្ធិ របស់រដ្ឋសហព័ន្ធ។ ការផ្តន្ទាទោសចំពោះបទល្មើស និងច្បាប់រក្សាសិទ្ធិ អាចរួមមាន ត្រូវចេញថ្លៃប្តូរឯកសារសម្រាប់ការប្រឡងដែលបានបើកចំហជាសាធារណៈ ឬត្រូវគេពិន័យមិនតិចជាង <u>៧៥០$</u> ទៅដល់ <u>៣០.០០០$</u> សម្រាប់បទល្មើសនីមួយៗ។
17 U.S.C. § 101 *et seq.*

ដើម្បីធ្វើយ៉ាងណាឲ្យទុកចិត្តបាននូវលទ្ធផលនៃការប្រឡង និងជៀសវាងការចំណាយសម្រាប់ការប្តូរឯកសារប្រឡង ក្រសួងអប់រំតម្រូវឲ្យសាលាមានច្បាប់ និងចាត់វិធានការ ដើម្បីការពារឯកសារប្រឡង។ វិធានការ ឬ ច្បាប់ មួយដែលតម្រូវសម្រាប់សាលាទាំងអស់គឺ មិនអនុញ្ញាតឲ្យមានគ្រឿងអេឡិចត្រូនិចនៅកន្លែងប្រឡង។ គ្រឿងអេឡិចត្រូនិចរួមមាន ទូរស័ព្ទដៃ, smartphones, E-readers, Nooks, Kindles, iPads, iPods, tablets, camera-ready devices, និងគ្រឿងអេឡិចត្រូនិចផ្សេងៗទៀត ដែលអាចប្រើដើម្បីថត ឬ ចម្លង ឯកសារប្រឡង អាចប្រើអ៊ិនធ័រណិត និង/ឬ ទាក់ទងជាមួយអ្នកដទៃទៀតនៅពេលប្រឡង PSSA ឬ Keystone។ សូមនិយាយជាមួយកូនរបស់លោកអ្នក ឲ្យពួកគេដឹងថាការមាន និង/ឬ ប្រើ ទូរស័ព្ទដៃ ឬគ្រឿងអេឡិចត្រូនិច នៅពេលប្រឡង PSSA ឬ Keystone អាចបណ្តាលឲ្យពួកគេទទួលផលវិបាកផ្សេងៗ។

បើសិនជាគេឃើញសិស្សប្រើ និង/ឬ មានទូរស័ព្ទដៃ ឬគ្រឿងអេឡិចត្រូនិចផ្សេងទៀតនៅក្នុងខ្លួន នៅពេលប្រឡង PSSA ឬ Keystone សាលានឹងទាក់ទងទៅលោកអ្នក។ សិស្សដែលមិនយកចិត្តទុកដាក់តាមការណែនាំនេះ នឹងទទួលវិន័យតាមច្បាប់របស់សាលា និងការតម្រូវរបស់ក្រសួងអប់រំ មិនឲ្យពិន្ទុដល់ការប្រឡងរបស់សិស្ស ហើយគេនឹងតម្រូវឲ្យសិស្សប្រឡងឡើងវិញទាំងអស់។ ជាបន្ថែមទៀត បុគ្គលិកសាលានឹងទុកគ្រឿងអេឡិចត្រូនិច ហើយនឹងឆែកឆេរមើលរូបភាពនៅគ្រឿងអេឡិចត្រូនិចនោះ។ បុគ្គលិកសាលាក៏សុំការអនុញ្ញាតដើម្បីឆែកឆេរកម្មវិធីផ្សេងទៀតរបស់គ្រឿងអេឡិចត្រូនិចនោះ។ បើសិនជាគេរកឃើញរូបថតអំពីការប្រឡង PSSA ឬ Keystone ឬបើសិនជាការសុំការអនុញ្ញាតដើម្បីឆែកឆេរកម្មវិធីផ្សេងទៀតរបស់គ្រឿងអេឡិចត្រូនិចនោះត្រូវបានគេបដិសេធ បុគ្គលិកសាលានឹងទុកគ្រឿងអេឡិចត្រូនិចនោះ ហើយដោយសារក្រសួងអប់រំនៃរដ្ឋធិនស៊ីលវេញ៉ា ជាម្ចាស់នៃការរក្សាសិទ្ធិឯកសារទាំងអស់ដែលមាននៅក្នុងការប្រឡង PSSA ឬ Keystone គេនឹងទាក់ទងទៅក្រសួងអប់រំនៃរដ្ឋធិនស៊ីលវេញ៉ា។

ក្រោយពេលប្រឡងចប់ ហើយឯកសារនៃការប្រឡងបានប្រគល់ឲ្យសាលាវិញហើយ បើសិនជាគេដឹងថាសិស្សប្រើ និង/ឬ មានទូរស័ព្ទដៃ ឬគ្រឿងអេឡិចត្រូនិចផ្សេងទៀតនៅក្នុងខ្លួននៅពេលប្រឡង គេនឹងធ្វើតាមច្បាប់ដាក់ទណ្ឌកម្មរបស់សាលា ហើយពិន្ទុរបស់សិស្សនឹងត្រូវគេចាត់ទុកថាជាមោឃៈ។